# ទ្រឹស្តីអំពីកំណាព្យ

»»**អ្វីទៅជាកំណាព្យ?** កំណាព្យជាកម្រងពាក្យសម្ដី មានពាក្យចួនរណ្ដំ ណែងណងយ៉ាងពិរោះ ដែលមានឃ្លា មានល្បះ គោរពតាមក្រឹត្យក្រម ដោយមានការកំណត់ពីកម្រិតចំនួនព្យាង្គទៅតាមវិធីសាស្ត្រនិពន្ធនៃបទនីមួយៗ។
»»កំណាព្យសម្ដែងចេញពីភាសាដួងចិត្តរបស់កវី ធ្វើឲ្យអ្នកអាន អ្នកស្ដាប់ រំភើប សប្បាយ ទុក្ខព្រួយ ស្រឡាញ់ ខឹងស្អប់ និងឈឺចាប់ជាមួយ។

ដើម្បីនិពន្ធកំណាព្យឲ្យបានល្អ យើងត្រូវស្គាល់ជាតុសំខាន់ៗរបស់កំណាព្យដូចខាងក្រោម៖

១. ព្យាង្គ

ជាសូរស្រៈ ឬព្យញ្ជនៈដែលមិនទាន់ប្រកប ឬក៏ប្រកបហើយមានសូរសំឡេងតែមួយ ទោះបីមានន័យក្ដី មិនមានន័យក្ដី។ ឧ. កូន ខ្មែរ គេ ដើប ឡើង ក ខ គ ឃ ង...

២. ពាក្យ

ជាសូរសំឡេងតែម្ដង ឬច្រើនដង ប៉ុន្តែមានន័យគ្រប់គ្រាន់។ ឧ. (ពាក្យ ១ព្យាង្គ) ខែ ថ្ងៃ ស្រី ប្រុស គេង... (ពាក្យ ២ព្យាង្គ) ព្រះចន្ទ អាទិត្យ នារី បុរស... (ពាក្យ ៣ព្យាង្គ) ព្រះចន្ទ្រា សុរិយា មនុស្សា ករុណា...

ពាក្យនៅក្នុងកំណាព្យចែកចេញជា ២ទៀតគឺ៖ ពាក្យពេចន៍ (ជាពាក្យសម្រាប់រំលេចន័យ ខ្លឹមសារសរសេរកំណាព្យឲ្យលេចឡើងក្នុងទម្រង់សិល្បៈខ្ពស់ដែលបង្កើតបានជារូបារម្មណ៍ ដើម្បីឲ្យអ្នកអាន អ្នកស្ដាប់ យល់ន័យដែលអ្នកកវីចង់និយាយ) និងពាក្យសម្ផស្ស (ជាពាក្យចួន ផ្ទួន រណ្ដំ នៅក្នុងកំណាព្យ)។

**ក. សម្ផស្សក្នុង៖** គឺជាចំណាប់ចួន ផ្ទួន រណ្ដំ នៅក្នុងឃ្លាជាមួយគ្នា។ ឧ. នឹកស្រុកនឹកស្រូវនៅឯស្រែ នឹកដៃពុកម៉ែធ្លាប់ថៃកូន ជួបមីងជួបមាបាត់តាដូន បាត់ពុកម៉ែសូន្យសល់ប្អូនបង។

ក្នុងឧទាហរណ៍កំណាព្យខាងលើនេះឃើញថា ស្រុក រណ្ដំនឹង ស្រូវ, ម៉ែ ចួននឹង ថៃ, ជួប ផ្ទួននឹង ជួប។ល។

**ខ. សម្ផស្សក្រៅ៖** គឺជាចំណាប់ចួន ផ្ទួន រណ្ដំដូចគ្នា ប៉ុន្តែនៅក្នុងពាក្យសម្ផស្សក្រៅនេះ ឆ្លងពីឃ្លាមួយ ទៅឃ្លាមួយ ឬក៏ពីល្បះមួយទៅល្បះមួយទៀត។

*ឃ្លា៖ នៅក្នុងកំណាព្យគឺជាព្យាង្គច្រើនរួមគ្នាទៅតាមវិធីសាស្ត្របទនីមួយៗដូចជាបទមេ៤ មាន៤ព្យាង្គក្នុង ១ឃ្លា។

*ល្បះ ឬល្បះខណ្ឌ៖ គឺឃ្លានៅក្នុងកំណាព្យរួមគ្នាដែលមានកំណត់នៅតាមវិធីសាស្ត្របទនីមួយៗ។ ឧ. បទពាក្យ ៤ មានឃ្លារួមគ្នាចំនួន ៤ បញ្ចប់ដោយខណ្ឌហៅថា ១ល្បះ។

## សូរសព្ទ ឬសូរសៀង (សំនៀង)

សូរសព្ទ សូរសៀង ឬសំនៀងមានន័យថា សំឡេង។ ចំពោះកំណាព្យ សំឡេងនេះសំខាន់ណាស់ព្រោះកំណាព្យល្អ គឺជាកំណាព្យដែលមានចំណាប់ចួនគោរពតាមសំឡេងព្យញ្ជនៈឃោសៈ ដូចជា "អ៊ិ" ត្រូវសរសេរឲ្យចួននឹង "អ៊ិ"។ សំឡេងព្យញ្ជនៈអឃោសៈ "អ" ត្រូវសរសេរចួននឹង "អ" ដូចគ្នា។ ឧ. ឃោសៈ៖ រៀន មាន ព្រាន យាន... អឃោសៈ៖ មាតា ជីតា ក្សត្រា ស្នេហា...

## ពាក្យចួនដែលមិនមែនជាកំណាព្យ

១. កម្រងកែវ៖ ពាក្យចួនដែរប៉ុន្តែគ្មានក្រឹត្យក្រម។ ឧ. សែនក្រុងពាលី សង់ផ្ទះជាដើម "ទើបអញខ្ញុំ ព្រះធរណី ចូរអ្នកអញ្ជើញមកយកក្រយាបូជាសារពើ ទៀនធូប ផ្កាលា បុប្ផាគន្ធមាលា ចេកអំពៅ ស្រូវអង្ករ ត្រាវ ដំឡូង ដូង ស្លា ល្ង សណ្ដែកទាំងឡាយដែលយើងខ្ញុំរៀបចំថ្វាយអ្នកហោង។

២. ពាក្យចួនប្រជាប្រិយ៖ សុភាសិត ឬពាក្យបណ្ដៅជាដើម។

៣. ពាក្យពលៈ ពាក្យសម្រាប់ក្មេងលេងពួន។

៤. ពាក្យកាព្យ៖ ពាក្យចួនមានក្រិត្យក្រមដូចជាកំណាព្យដែរ ប៉ុន្តែជាភាសាសម្បកក្រៅ។

* *

*